**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៩១ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើត និងដាក់ឲ្យដំណើរការទីភ្នាក់ងារ ប្រតិបត្តិការពិសេស នៃក្រសួងសុខាភិបាល

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៨/៣៤៦ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៨ ស្តីពី គោលការណ៍រួមនៃការបង្កើត និងការដាក់ឲ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល



www.pheakdeylaw.com

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើត និងដាក់ឲ្យដំណើរការបន្ថែមទីភ្នាក់ងារប្រតិបត្តិការពិសេសចំនួន០៦នៅតាមបណ្តាអង្គភាពសុខាភិបាល នៃក្រសួងសុខាភិបាល មានដូចខាងក្រោម ៖

១- មន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង

២- មន្ទីរពេទ្យបង្អែកខេត្តស្ទឹងត្រែង

៣- មណ្ឌលសុខភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិស្ទឹងត្រែង ខេត្តស្ទឹងត្រែង

៤- មន្ទីរពេទ្យបង្អែកស្រុក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

៥- មន្ទីរពេទ្យបង្អែកស្រុក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

៦- មន្ទីរពេទ្យបង្អែកស្រុក និងមណ្ឌលសុខភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិបាកាន ខេត្តពោធិ៍សាត់ ។

**មាត្រា២.-**

ទីភ្នាក់ងារប្រតិបត្តិការពិសេសនៃក្រសួងសុខាភិបាលដូចមានចែងក្នុងមាត្រា១ នៃអនុក្រឹត្យនេះ គឺជាភ្នាក់ងារមួយរបស់ក្រសួងសុខាភិបាល ដែលមានមុខងារពិសេសក្នុងការផ្តល់សេវាសុខាភិបាលជូនប្រជាពលរដ្ឋ ហើយស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងសុខាភិបាល និងមានភារកិច្ចចម្បងៗ ដូចខាងក្រោម ៖

- ផ្តល់សេវាសុខភាពសាធារណៈប្រកបដោយគុណភាព និងប្រសិទ្ធភាព ស្របតាមតម្រូវការរបស់អ្នកប្រើប្រាស់សេវា
- លើកកម្ពស់ការគ្រប់គ្រងផ្អែកលើលទ្ធផលការងារ សំដៅកែប្រែផ្នត់គំនិត និងអាកប្បកិរិយាមន្ត្រីរាជការ ស្របតាមលក្ខណសម្បត្តិរបស់រដ្ឋបាលសាធារណៈ
- អភិវឌ្ឍសមត្ថភាពមន្ត្រីក្នុងការផ្តល់សេវាសុខាភិបាលសាធារណៈ។

ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិនីមួយៗមានតួនាទីសម្របសម្រួល និងគាំទ្រផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងការងារគ្រប់គ្រងដល់អង្គភាពសុខាភិបាលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។

**មាត្រា៣.-**

ទីភ្នាក់ងារប្រតិបត្តិការពិសេសដែលជាមន្ទីរពេទ្យបង្អែកខេត្ត ដូចមានក្នុងមាត្រា១ ត្រូវដឹកនាំ និងគ្រប់គ្រងដោយប្រធានមន្ទីរពេទ្យបង្អែកខេត្តនីមួយៗ។

ទីភ្នាក់ងារប្រតិបត្តិការពិសេសដែលស្ថិតនៅតាមបណ្តាការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ដូចមានចែងក្នុងមាត្រា១ ត្រូវដឹកនាំ និងគ្រប់គ្រងដោយប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិនីមួយៗ។



www.pheakdeylaw.com

**មាត្រា៤.-**

សិទ្ធិ និងការទទួលខុសត្រូវរបស់ប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេសនៃក្រសួងសុខាភិបាល ត្រូវកំណត់ឲ្យបានច្បាស់លាស់នៅក្នុងលក្ខខណ្ឌបេសកកម្ម និងក្នុងកិច្ចសន្យាគ្រប់គ្រង។

លក្ខខណ្ឌបេសកកម្ម និងកិច្ចសន្យាគ្រប់គ្រងគំរូ ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា៥.-**

ប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេស នៃបណ្តាអង្គភាពសុខាភិបាលនីមួយៗត្រូវទទួលខុសត្រូវក្នុងដំណើរការ និងការគ្រប់គ្រងទីភ្នាក់ងារប្រតិបត្តិការពិសេសរបស់ខ្លួន ចំពោះប្រធានមន្ទីរសុខាភិបាលខេត្តដែលទីភ្នាក់ងារប្រតិបត្តិការពិសេសស្ថិតនៅ ។

**មាត្រា៦.-**

មន្ត្រីដែលបម្រើការងារក្នុងទីភ្នាក់ងារប្រតិបត្តិការពិសេសនៅតាមបណ្តាអង្គភាពនៃក្រសួងសុខាភិបាល ដូចបានកំណត់ក្នុងមាត្រា១ ជាមន្ត្រីក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ឬ បុគ្គលិកជាប់កិច្ចសន្យាដែលកំពុងបម្រើការងារក្នុងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់ក្រសួងសុខាភិបាល។

មន្ត្រីរាជការ និងបុគ្គលិកទាំងនេះ ត្រូវចុះកិច្ចសន្យាការងារជាមួយប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេសនីមួយៗ តាមរយៈអ្នកគ្រប់គ្រងមន្ត្រីផ្ទាល់។

**មាត្រា៧.-**

មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា ដែលបម្រើការងារនៅក្នុងទីភ្នាក់ងារប្រតិបត្តិការពិសេសនៃក្រសួងសុខាភិបាលត្រូវទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្តដែលបានមកពីការបែងចែកប្រាក់សេវាហិរញ្ញប្បទាន ប្រាក់ធានារ៉ាប់រងសង្គម ប្រាក់មូលនិធិសមធម៌ និងប្រាក់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ បន្ថែមលើប្រាក់បៀវត្ស និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស។

កម្រិតប្រាក់ឧបត្ថម្ភលើកទឹកចិត្តខាងលើនេះ ត្រូវអនុវត្តតាមការណែនាំជាក់ស្តែងរបស់ក្រសួងសុខាភិបាល។ បន្ថែមលើនេះ ប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេសនីមួយៗ អាចផ្តល់ជូនប្រាក់ឧបត្ថម្ភលើកទឹកចិត្តដល់មន្ត្រី និងបុគ្គលិកទៅតាមលទ្ធផលការងារ និងស្ថានភាពជាក់ស្តែង នៃទីភ្នាក់ងារប្រតិបត្តិការពិសេសស្ថិតនៅ។

**មាត្រា៨.-**

ការបើកប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ត្រូវធ្វើឡើងនៅតាមអង្គភាពដែលទីភ្នាក់ងារប្រតិបត្តិការពិសេសគ្របដណ្តប់ តាមរយៈការបើកផ្តល់ដោយផ្ទាល់ដៃ ឬតាមប្រព័ន្ធធនាគារ។

**មាត្រា៩.-**

ប្រភពធនធាន និងចំណូលថវិការបស់ទីភ្នាក់ងារប្រតិបត្តិការពិសេសនៃក្រសួងសុខាភិបាលបានមកពីៈ

- ថវិកាជាតិ
- ប្រាក់សេវាហិរញ្ញប្បទាន
- ប្រាក់ធានារ៉ាប់រងសង្គម
- ប្រាក់មូលនិធិសមធម៌ និង
- ប្រាក់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍។



www.pheakdeylaw.com

**មាត្រា១០.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍន៍វិស័យសុខាភិបាលត្រូវធានាថវិកាដែលត្រូវផ្តល់ឲ្យទីភ្នាក់ងារប្រតិបត្តិការពិសេសនីមួយៗបានទាន់ពេលវេលា។

ទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលជាសេនាធិការ មានតួនាទី សម្របសម្រួល ជំរុញ និងតាមដានការអនុវត្តរបស់ទីភ្នាក់ងារប្រតិបត្តិការពិសេសទាំងនេះ។

**មាត្រា១១.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាលរដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**សុខ អាន**

<u>កន្លែងទទួល :</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com